គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២

# ការលុបឈ្មោះទណ្ឌិតជាប់ពន្ធនាគារចេញពីបញ្ជីបោះឆ្នោតដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងការសំរេចរបស់គ.ជ.ប៖ ខុសច្បាប់ និងប៉ះពាល់សិទ្ធិបោះឆ្នោត

ខុមហ្វ្រែលបានសាកល្បងពិភាក្សាលើអង្គហេតុនៃករណីស្ដីពីការលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីបោះឆ្នោត និងអង្គច្បាប់ ព្រមទាំងនីតិវិធី ។ ព្រោះថា សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង គ.ជ.ប ហាក់ដូចជាខ្វះមូលដ្ឋានក្របខណ្ឌច្បាប់ និងនីតិវិធីជាក់លាក់ណាចែងពីការលុបឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតដែលត្រូវបានតុលាការផ្ដន្ទាទោសផ្សេងពីបទល្មើសបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត ក្នុងករណីពិសេស ឬ ប្រចាំឆ្នាំនោះឡើយ ។

នៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១២ ក្រុមប្រឹក្សាសង្កាត់បឹងរាំងបានសម្រេចលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីបោះឆ្នោតឆ្នាំ ២០១២ ដែលមានសម្លេងគាំទ្ររបស់សមាជិកក្រុមប្រឹក្សាសង្កាត់ចំនួន ៥រូប លើ ៧រូប ដោយផ្អែកលើមាត្រា ៥០ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសាលដីកាតុលាការកំពូល លេខ៣២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១១ ក្នុងករណីថាជនដែលមានទោសគ្មានសិទ្ធិមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ បន្ទាប់ពីការសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំងរួចមក លោក ជួង ជូងី ដែលជាមេធាវីរបស់លោក សម រង្ស៊ី បានប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំងខណ្ឌដូនពេញ រាជធានីភ្នំពេញ ទៅក្រុមប្រឹក្សាជំនុំជម្រះ គ.ជ.ប ទាក់ទងទៅនឹងសាលដីកាលេខ ៣២ ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១១ របស់តុលាការកំពូល មិនត្រូវបានអនុវត្តដោយតុលានេះនៅឡើយ, មាត្រា៥០ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងតែអំពីការចុះឈ្មោះបោះឆ្នោត, ការលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីបោះឆ្នោតគឺត្រូវផ្អែកលើសេចក្ដីណែនាំរួមស្ដីពីការពង្រឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតលេខ ០២៧ សណន ចុះថ្ងៃ០៣ ខែកញ្ញា ឆ្នាំ ២០១០ របស់ គ.ជ.ប ប៉ុន្តែក្រុមប្រឹក្សាសង្កាត់បឹងរាំងមិនមានលិខិតបញ្ជាក់ពីការដកហូតសិទ្ធិបោះឆ្នោតលោកសម រង្ស៊ី, ករណីរបស់លោកសម រង្ស៊ី កំពុងតែត្រូវបានចាត់ការតាមនីតិវិធីដោយតុលាការកំពូលលើបណ្ដឹងសើរើ, ការចាត់ចែងការអនុវត្តសាលដីកាតុលាការកំពូលរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំងមិនត្រូវតាមគត្តិច្បាប់, និងតុលាការកំពូលអាចនឹងព្យួរការអនុវត្តទោសករណីលោកសម រង្ស៊ី។

ច្បាប់អនុញ្ញាតឲ្យប្ដឹងជនណាម្នាក់បានលុះត្រាតែជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់តាមការតម្រូវនៃមាត្រា៥០ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមកសុំចុះឈ្មោះបោះឆ្នោត។ នីតិវិធី និងសៀវភៅណែនាំរបស់ គ.ជ.ប បានអនុញ្ញាតជនណាម្នាក់អាចប្ដឹងជំទាស់ទៅនឹងអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលជននោះគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតដោយស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ប៉ុន្តែគ្មាននីតិវិធី និងការណែនាំឲ្យប្ដឹងជំទាស់ដកសិទ្ធិបោះឆ្នោតដោយដកឈ្មោះចេញពីបញ្ជីបោះឆ្នោត ព្រោះជននោះជាទណ្ឌិតជាប់ពន្ធនាគារ។

ជាទូទៅការប្ដឹងជំទាស់ឲ្យដកឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយសារបញ្ហាសញ្ញាតិ និងអាយុ ជាលក្ខខណ្ឌចាំបាច់ដាច់ខាត ដែលមានចែងក្នុងបទដ្ឋានលិខិតតូបករណ៍អន្តរជាតិស្ដីពីសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត។

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ប៉ុន្តែសម្រាប់លក្ខខណ្ឌមានទីលំនៅ ទណ្ឌិតជាប់ពន្ធនាគារ ឬ ជនវិកលចរិក ជាលក្ខខណ្ឌ តែមិនដាច់ខាត។ មានន័យថា ការប្ដឹងជំទាស់លើជនណាម្នាក់ក្នុងលក្ខខណ្ឌនេះអាចមិនឲ្យអនុវត្ត។ គ.ជ.ប ក៏បានយល់អំពីបញ្ហានេះដែរ កន្លងមកតែពន្យល់ថា គ.ជ.ប អនុវត្តតាមច្បាប់ ហើយ គ.ជ.ប គ្មានសិទ្ធិដកឈ្មោះនរណាម្នាក់បានទេសូម្បីឈ្មោះស្ទួនចេញពីបញ្ជីបោះឆ្នោតក្នុងកំឡុងពេលចុះឈ្មោះ ។

ចំណែកឯសាលដីកាលេខ ៣២ ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១១ របស់តុលាការកំពូលបានកាត់ទោសកំបាំងមុខឲ្យលោក សម រង្ស៊ីជាប់ទោសពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ញុះញង់ និងបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ដែលពាក់ព័ន្ធទៅនឹងទោសព្រហ្មទណ្ឌ ត្រូវបានលោក សម រង្ស៊ីបន្តដាក់ពាក្យបណ្ដឹងកាលពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១២ ដើម្បីឲ្យមានការសើរើនៅតុលាការកំពូល ។ បើផ្អែកលើមាត្រា ៤៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើតុលាការកំពូលកំពុងតែចាត់ការបណ្ដឹងសើរើករណីលោក សម រង្ស៊ី នោះតុលាការកំពូលអាចព្យួរការអនុវត្តទោសបាន ។

នៅរសៀលថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០១២ ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបើកសវនាការដើម្បីដោះស្រាយបណ្ដឹងជាសាធារណៈទៅលើបណ្ដឹងដែលលោក ជួង ជូងី ជាមេធាវីលោក សម រង្ស៊ី ក្នុងការប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំង ក្នុងការលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីបោះឆ្នោត ។ ជាលទ្ធផលក្រុមប្រឹក្សាជំនុំជម្រះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចតម្កល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់បឹងរាំងទុកជាបានការក្នុងការលុបឈ្មោះលោក សម រង្ស៊ី ចេញពីបញ្ជីបោះឆ្នោត ។ ការដោះស្រាយបណ្ដឹង ហើយតំកល់ការសម្រេចសេចក្ដីរបស់ក្រុមប្រឹក្សានេះ ហាក់ដូចជាអនុវត្តខុសពីទម្រង់ និងគតិច្បាប់របស់ស្ថាប័ន ព្រោះ គ.ជ.ប បានយោងមាត្រា៥០ ដែលមិនទាក់ទិនឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ដកសិទ្ធិអ្នកបោះឆ្នោតដោយឈ្មោះនរណាម្នាក់ចេញពីក្នុងបញ្ជីបោះឆ្នោត ។

មាត្រា ៥០ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងជំពូកទី ៦ សម្រាប់ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោតបានចែងថា "*ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោត ។ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖*

- *មានសញ្ជាតិខ្មែរ ។*
- *មានអាយុ ១៨ ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។*
- *មានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត ។*
- *មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ។*
- *ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។*

*គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីអនុវត្តជាក់ស្ដែងនូវវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ។*"

យោងតាមមាត្រា ៥០ថ្មីនៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រៀបរាប់តែអំពីលក្ខខណ្ឌតំរូវឲ្យប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោត ប៉ុន្តែមាត្រានេះពុំបានចែងពីប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយនោះទេ ឬទណ្ឌិតដែលត្រូវបានតុលាការផ្ដន្ទាទោសក្រៅពីបទល្មើសបោះឆ្នោតដែលមានចែងនៅក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវលុបចេញពីបញ្ជីបោះឆ្នោតនោះទេ ។ ព្រះរាជាណាចក្រកម្ពុជា មានក្រមព្រហ្មទណ្ឌដែលចែង

យ៉ាងច្បាស់ និងជាក់លាក់អំពីប្រភេទនៃបទល្មើស និងលក្ខណ្ឌដែលថៅក្រមមានសិទ្ធិក្នុងការដកហូតសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយនៅពេលដែលបបុគ្គលនោះត្រូវបានតុលាការផ្តន្ទាទោសតាមបទល្មើសដែលមានចែងនៅក្នុងច្បាប់ និងមានសាលក្រម ឬសាលដីការជាស្ថាពរ ក៍ប៉ុន្តែទាក់ទងទៅនឹងនីតិវិធី ក្នុងការលប់ឈ្មោះទណ្ឌិតចេញពីបញ្ជីបោះឆ្នោតប្រចាំឆ្នាំ និងស្ថាប័ន ឬអង្គដែលជាអ្នកអនុវត្តនៅក្នុងកំឡុងពេលចុះឈ្មោះ និងពេលពិនិត្យបញ្ជីឈ្មោះនោះ គឺពុំទាន់ឃើញមាននៅឡើយទេ ។ ម្យ៉ាងវិញទៀត ជំពូកទី ១១នៃច្បាប់បោះឆ្នោតនេះ បានអនុញ្ញាតឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលុបឈ្មោះអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតរួចហើយ ក្នុងករណីដែលអ្នកមានសិទ្ធិបោះឆ្នោតនោះប្រព្រឹត្តបទល្មើសណាមួយទាក់ទងទៅនឹងការបោះឆ្នោត ដូចជាការប្រើកម្លាំង ឬអំពើហឹង្សា ឬបំភិតបំភ័យមិនឲ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហឹង្សាទៅលើបេក្ខជន ឬគណបក្សនយបាយដទៃ ការបង្កការរំខានមិនឲ្យដំណើរការបោះឆ្នោតបាន ការបង្កការរំខានមិនឲ្យរាប់សន្លឹកឆ្នោតបាន ការធ្វើឲ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត និងការទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាសជាដើម ដែលករណីខាងលើនេះ បានចង្អុលបង្ហាញនូវបទល្មើសបោះឆ្នោតយ៉ាងច្បាស់លាស់ និងការអនុញ្ញាត្តិឲ្យ គ.ជ.ប មានអំណាចពេញលេញដែលស្របតាមគតិច្បាប់ ក៍ដូចជាទម្រង់ច្បាប់ក្នុងការលប់ឈ្មោះអ្នកបោះឆ្នោតដែលមានឈ្មោះរួចមកហើយក្នុងបញ្ជីឈ្មោះបោះឆ្នោតចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅពេលដែលអ្នកបោះឆ្នោតនោះត្រូវបានផ្តន្ទាទោសនូវបទល្មើសដូចដែលមានចែងនៅក្នុងជំពូកទី១១នោះ រីឯការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតនូវទណ្ឌិតដែលប្រព្រឹត្តអំពើផ្សេងពីអ្វីដូចដែលមានចែងក្នុងជំពូកខាងលើនេះ គឺមិនទាន់មានទេ។

មាត្រា ៥០ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាចពន្យល់បានថា លោក សម រង្ស៊ី អាចបាត់បង់សិទ្ធិបោះឆ្នោត ប៉ុន្តែក្នុងករណីឈ្មោះលោក សម រង្ស៊ីមាននៅក្នុងបញ្ជីបោះឆ្នោត និងមានការរួចទោស ឬបញ្ចប់ទោស ក្នុងកំឡុងពេលមុនថ្ងៃបោះឆ្នោត លោក សម រង្ស៊ីក៏អាចបោះឆ្នោតបានដែរ ។

ក្នុងកំឡុងពេលចុះឈ្មោះ និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត គ.ជ.ប មានបទបញ្ជា និងនីតិវិធី និងសៀវភៅណែនាំរបស់ខ្លួនសម្រាប់មន្ត្រី គ.ជ.ប ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ។ នីតិវិធី និងការណែនាំនេះអនុញ្ញាតឲ្យស្មៀន ឬក្រុមប្រឹក្សាឃុំ សង្កាត់ លុបឈ្មោះនរណាម្នាក់ចេញពីបញ្ជី ប៉ុន្តែមិនមែនឲ្យ "ដកសិទ្ធិបោះឆ្នោតនរណាម្នាក់ទេ" ។ នីតិវិធី និងសេចក្តីណែនាំមានគោលបំណងដើម្បីពង្រឹងគុណភាព និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតដោយដកឈ្មោះ ស្ទួន និងអ្នកស្លាប់ ។ ក្នុងនីតិវិធី និងសៀវភៅណែនាំនេះ ក៏ពុំមានចែងឲ្យស្មៀន ក្រុមប្រឹក្សាឃុំសង្កាត់ ឬ គ.ជ.ប ខ្លួនឯងដកសិទ្ធិអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោត ព្រោះនរណាម្នាក់ជាទណ្ឌិត ឬវិកលចរិកនោះឡើយ ។

នៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១២ តំណាងគ.ជ.ប បែរជាលើកយកមាត្រា ៥៣ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរៀបចំអំពីគ.ជ.បត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំសង្កាត់ឲ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសំរាប់ឃុំសង្កាត់ ។ ប៉ុន្តែគ្មានការរៀបរាប់របស់មាត្រានេះ ឬគ្មាននីតិវិធី និងការណែនាំណាមួយឲ្យក្រុមប្រឹក្សាឃុំសង្កាត់មានតួនាទីទៅដកសិទ្ធិអ្នកបោះឆ្នោតដោយលប់ឈ្មោះអ្នកស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារឡើយ ។ តំណាងគ.ជ.ប អាចមិនច្បាស់លាស់អំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ជួយសំអាតបញ្ជីឈ្មោះ ឬធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ ដោយដក ឈ្មោះស្ទួន ឬអ្នកស្លាប់ ។

សំណួរអាចលើកឡើងថា តើ គ.ជ.ប អាចធានាថាទណ្ឌិតជាប់ពន្ធនាគារ (នៅក្នុងពន្ធនាគារ ឬនៅក្រៅពន្ធនាគារ ដោយការព្យួរទោស ) មិនអាចបោះឆ្នោតបាន បើសិនមិនលុបឈ្មោះចេញពីបញ្ជី?

ក្នុងករណីនេះសាកល្បងផ្តល់យោបល់ខ្លះដែលទណ្ឌិតជាប់ពន្ធនាគារមិនអាចទៅបោះឆ្នោតបាន។ គ.ជ.ប អាចផ្តល់ព័ត៌មានទៅក្រសួងមហាផ្ទៃ និងមន្ត្រីពន្ធនាគារអំពីទណ្ឌិតជាប់ពន្ធនាគារមិនឲ្យបោះឆ្នោត ។ ដូចនេះមន្ត្រីពន្ធនាគារនៅថ្ងៃបោះឆ្នោតនឹងមិនអនុញ្ញាតឲ្យទណ្ឌិតទាំងនោះទៅបោះឆ្នោតទេ ។

សម្រាប់ទណ្ឌិតជាប់ពន្ធនាគារ ដែលត្រូវបានព្យួរទោសឲ្យនៅក្រៅពន្ធនាគារ ក្រសួងយុត្តិធម៌គួរផ្តល់ព័ត៌មានទណ្ឌិតទាំងនោះឲ្យ គ.ជ.ប ដើម្បីជូនដំណឹងទៅមន្ត្រីការិយាល័យបោះឆ្នោត នូវបញ្ជីឈ្មោះទណ្ឌិតទាំងនោះដែលមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ។

ជាសរុប បន្ទាប់ពីសិក្សាករណីលោក សម រង្ស៊ី និងក្របខណ្ឌច្បាប់ ក្រុមប្រឹក្សាឃុំ សង្កាត់ និងគ.ជ.ប ធ្វើការសំរេចដកឈ្មោះទណ្ឌិតជាប់ពន្ធនាគារ ចេញពីបញ្ជីបោះឆ្នោតនោះ គឺគ្មានបញ្ញត្តិច្បាប់ ឬនីតិវិធីណាមួយដែលឲ្យក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តដូចនេះទេ ។ ក្នុងករណីដកឈ្មោះទណ្ឌិត ចេញពីបញ្ជីឈ្មោះបោះឆ្នោត វាអាចធ្វើឲ្យពួកគេបាត់បង់ សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត ។ នៅកម្ពុជារយៈពេលនៃការចុះឈ្មោះទៅដល់ថ្ងៃបោះឆ្នោតគឺមានរហូតដល់ប្រាំបួនខែ ដែលក្នុងកំឡុងពេលនេះ ទណ្ឌិតខ្លះបានបញ្ចប់ទោសរបស់ពួកគេ ឬជនវិកលចរិកអាចជាសះស្បើយ ។

ខុមហ្វ្រែលយល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញ បានតម្កល់ការសំរេចរបស់ គ.ជ.ប នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១២ អំពីករណីសមរង្ស៊ី ដែលធ្វើឲ្យមានការអនុវត្តករណីគំរូដែលប៉ះពាល់សិទ្ធិបោះឆ្នោត ដោយខ្វះបញ្ញត្តិច្បាប់ និងនីតិវិធីគ្រប់គ្រាន់ ។ ក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចក្នុងការបកស្រាយនូវបទបញ្ញាត្តិ ឬក៏វិវាទដែលទាក់ទងនឹងអង្គច្បាប់ពិសេសបញ្ញាត្តិដែលណែនាំឲ្យលុបឈ្មោះទណ្ឌិតចេញពីបញ្ជីបោះឆ្នោតដែលត្រូវបានផ្តន្ទាទោសក្រៅពីបទល្មើសបោះឆ្នោត។

***<u>បេសកម្ម</u>*** *៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/* ***ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌*** *តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/* ***ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត*** *តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។*